# ព្រះរាជក្រម

នស/រកម/០៦១១/០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនអគ្គិសនីវៀតណាម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖



ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនអគ្គិសនីវៀតណាម

**មាត្រា ១.-**

អនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនអគ្គិសនីវៀតណាម ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី តាមរយៈខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២២០ គីឡូវ៉ុល អានុភាព ២០០ មេហ្គាវ៉ាត់ ពីក្រុមហ៊ុនអគ្គិសនីវៀតណាម តភ្ជាប់ពីអនុស្ថានីយចូវដុក-វៀតណាម ឆ្លងតាមភ្នំដិន-កម្ពុជា មកខេត្តតាកែវ-ភ្នំពេញ រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីវៀតណាម ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០០ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម និងកិច្ចព្រមព្រៀងវិសោធនកម្មលើកទី ១ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៣ នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា និងកិច្ចព្រមព្រៀងវិសោធនកម្មលើកទី ២ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម ។ ការជានានេះ មានអត្ថបទទាំងស្រុង ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តលិខិតជានាទូទាត់នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម/០៦១១/០០៧

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខៈ ៤៩៣ ច.ល

ការដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មិថុនា ឆ្នាំ២០១១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនអេន

3/3